# អនុក្រឹត្យ

## ស្តីពី

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ
## របស់មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ

# I. ផ្នែកទីទី... 

## ១. អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៤

**អនុក្រឹត្យលេខ ១៧ អនក្រ**

ស្តីពីតួនាទី ភារកិច្ច និង របៀបរៀបចំ

របស់ មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ត្រាស់បង្គាប់តែងតាំងប្រតិភូ នៃរាជរដ្ឋាភិបាល ទទួលបន្ទុកដឹកនាំមជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកដឹកនាំមជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ

**សម្រេច**

មាត្រា ១ ៖ មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ "យុវនិតិសម្បទា" ជាស្ថាប័នចំណុះរាជរដ្ឋាភិបាលដែលមានសមត្ថកិច្ចគ្រប់គ្រងក្មេងពីអាយុ ៧ ឆ្នាំ ដល់ ១៧ ឆ្នាំ ប្រព្រឹត្តអំពើអបាយមុខ ចោរកម្ម ក្នុងទូទាំងប្រទេស និង មានតួនាទីកែប្រែ អភិវឌ្ឍន៍ធនធានមនុស្ស អោយមានការរីកចំរើនទាំងជីវភាព ខាងស្មារតី និង សម្ភារៈ ដោយប្រែក្លាយពីជនគ្មានវិន័យ គ្មានសីលធម៌ ... ទៅជាពលរដ្ឋស្អាតស្អំ ប្រកបដោយវិន័យថ្លៃថ្នូរ ។

មាត្រា ២ ៖ មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ មានភារកិច្ចសំខាន់ៗ ដូចតទៅ ៖

- ចូលរួមសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីទទួលយកក្មេង ដែលប្រព្រឹត្តិអំពើអបាយមុខ ចោរកម្មមកគ្រប់គ្រង និង ស្រាវជ្រាវរកគ្រួមគ្រួសារ អាណាព្យាបាលរបស់គេ ដោយធ្វើកោសល្យវិច័យ ។
- បែងចែកការគ្រប់គ្រងតាមភេទ តាមអាយុ តាមការប្រព្រឹត្ត. វ័យ. ភេទ ។
- អប់រំសីលធម៌រស់នៅ ដើម្បីប្រែក្លាយគេអោយទៅជាពលរដ្ឋល្អថ្លៃថ្នូរ សំរាប់សង្គមជាតិ ។
- អប់រំបំពេញវិជ្ជា និង បណ្តុះបណ្តាលវិជ្ជាជីវៈ តាមរូបភាព អញ្ជើញគ្រូរបស់ ក្រសួងអប់រំ យុវជន និង កីឡា មកជួយ ឬ ជួលគ្រូបង្ហាត់ជំនាញដូចជា កាត់ដេរ ជួសជុលគ្រឿងយន្ត ជាងឈើ ជាងកំបោរ កែច្នៃគ្រឿងសង្ហារឹម ដាំដុះ ចិញ្ចឹមសត្វ ។ល។ និង មានផ្តល់ជាលិខិតទទួលស្គាល់មុខវិជ្ជាជីវៈ សំរាប់សំរួលដល់ការទៅរកប្រកបរបរចិញ្ចឹមជីវិតរបស់គេ នៅពេលវិលទៅរួមរស់ជាមួយគ្រួសារ និង អាណាព្យាបាល ។
- សហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមនានា ដើម្បីអភិវឌ្ឍន៍មជ្ឈមណ្ឌល ។

មាត្រា ៣ : រចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលរួមមាន ៖

១- ខុទ្ទកាល័យ

២- នាយកដ្ឋានបណ្តុះបណ្តាល

៣- នាយកដ្ឋានគ្រប់គ្រង

៤- នាយកដ្ឋានទំនាក់ទំនងជំនួយ

រចនាសម្ព័ន្ធនេះមានការកែប្រែទៅតាមករណីជាក់ស្តែង ។

ខុទ្ទកាល័យ នាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការ ។

មាត្រា ៤ : ការរៀបចំតួនាទី ភារកិច្ច និង សិទ្ធិរបស់ខុទ្ទកាល័យ នាយកដ្ឋាន និង ការិយាល័យនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់មជ្ឈមណ្ឌល ។

មាត្រា ៥ : មជ្ឈមណ្ឌល អាចចេញប្រកាសរួម ក្នុងនាមអន្តរក្រសួងលើករណី មានការចាត់តាំងដល់តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ខ្លួនជាមួយក្រសួង ស្ថាប័នផ្សេងៗទៀត ។

មាត្រា ៦ : គ្របខ័ណ្ឌ មន្ត្រី បុគ្គលិករាជការ និង ទីប្រឹក្សាឧបការី របស់មជ្ឈមណ្ឌល ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

មាត្រា ៧ ការចំណាយទាំងអស់សំរាប់សកម្មភាពរបស់មជ្ឈមណ្ឌល ជាបន្ទុករបស់ថវិកាជាតិ ។

មាត្រា ៨ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រតិភូនៃរាជរដ្ឋាភិបាលទទួលបន្ទុកដឹកនាំមជ្ឈមណ្ឌល គ្រប់គ្រងយុវទោសករ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួង និង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា ៩ អនុក្រឹត្យនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

## រចនាសម្ព័ន្ធមជ្ឈមណ្ឌលគ្រប់គ្រងយុវជនទោសករ

# « យុវនិកសម្បទា »

